ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ៣៦៦....សហវ.ប្រក

ប្រកាស

ស្ដីពី

ការកែសម្រួលគោលការណ៍និងនីតិវិធី នៃការកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូលផ្ទុកក្នុង
ក្នុងតែន័រដែលត្រូវឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កែន

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

  បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦ /១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ ស្ដីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញប្រកាសលេខ ៨៣៧ សហវ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីការកំណត់ប្រភេទទំនិញ និងកម្រៃសេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូលផ្ទុកក្នុងកុងតែន័រតាមប្រព័ន្ធ TC-SCAN
- យោងតាមសំណូមពរការងារចាំបាច់



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកែលម្អបន្ថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញបែបបទបញ្ចេញទំនិញពីគយ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូល ដែលត្រូវឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន ប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះទំនិញនាំចេញ-នាំចូលដែលផ្ទុកក្នុងកុងតែន័រ។

**ប្រការ ៤.-**

ត្រូវបានកែសម្រួលគោលការណ៍និងនីតិវិធីនៃការកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូល ដែលត្រូវឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន ដូចខាងក្រោម÷

១. ការកំណត់ទំនិញនាំចេញ-នាំចូលផ្ទុកក្នុងកុងតែន័រ ឱ្យឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន ត្រូវផ្អែកលើគោលការណ៍នៃការគ្រប់គ្រងហានិភ័យ ឬតាមការស្នើសុំរបស់ម្ចាស់ទំនិញ

២. ទំនិញនាំចេញ-នាំចូលរបស់សមាជិកក្រុមធុរជនល្អបំផុត ឬប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត និងវិនិយោគិនតំបន់សេដ្ឋកិច្ចពិសេស ជាកម្មវត្ថុនៃការលើកលែងការត្រួតពិនិត្យដោយម៉ាស៊ីនស្កេន ប៉ុន្តែអាចតម្រូវឱ្យឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន តាមគោលការណ៍ជ្រើសរើសដោយចោះៗ ឬតាមព័ត៌មានហានិភ័យដែលរដ្ឋបាលគយបានកំណត់

៣. ទំនិញនាំចូលដែលប្រើប្រាស់របបគយឆ្លងកាត់ ទៅបំពេញបែបបទបញ្ចេញទំនិញពីគយនៅតាមបណ្តាអង្គភាពគយនិងរដ្ឋាករផែស្ងួតនានា ត្រូវប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេននៅផែស្ងួត តាមការកំណត់របស់រដ្ឋបាលគយ

៤. ចំពោះទំនិញនាំចេញផ្ទុកក្នុងកុងតែន័រ ត្រូវអនុវត្តដូចខាងក្រោម÷

ក. ទំនិញរបស់វិនិយោគិនកាត់ដេរនិងវាយនភ័ណ្ឌ និងទំនិញរបស់គម្រោងវិនិយោគទទួលបានការលើកទឹកចិត្តផ្សេងទៀត ដែលបានត្រួតពិនិត្យមុនពេលផ្ទុកចូលកុងតែន័ររួចដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច ត្រូវបានលើកលែងការត្រួតពិនិត្យដោយម៉ាស៊ីនស្កេន លុះត្រាតែមានការស្នើសុំពីម្ចាស់ទំនិញ ឬព័ត៌មានហានិភ័យដែលរដ្ឋបាលគយបានកំណត់

ខ. ទំនិញនាំចេញផ្សេងទៀតដែលត្រូវត្រួតពិនិត្យដោយម៉ាស៊ីនស្កេន អាចធ្វើការត្រួតពិនិត្យនេះនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត ឬនៅមាត់ច្រកនាំចេញ តាមសំណើរបស់ម្ចាស់ទំនិញ ឬតាមការកំណត់របស់រដ្ឋបាលគយ។

**ប្រការ ៥.-**

ទំនិញនាំចេញ- នាំចូលផ្ទុកក្នុងកុងតែន័រទាំងអស់ គឺជាកម្មវត្ថុនៃការបង់កម្រៃស្កែនតាមបទប្បញ្ញត្តិជាធរមាន លើកលែងតែ÷

- ទំនិញនាំចេញជាផលិតផលសម្រេចរបស់វិនិយោគិនកាត់ដេរ ដែលបានត្រួតពិនិត្យមុនពេលផ្ទុកចូលកុងតែន័ររួចដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច
- ទំនិញនាំចេញ- នាំចូល របស់វិនិយោគិនតំបន់សេដ្ឋកិច្ចពិសេស
- ទំនិញនាំចេញ- នាំចូលរបស់ស្ថាប័នរដ្ឋ, អង្គទូត ឬអង្គការមានអភ័យឯកសិទ្ធិការទូត, អង្គការអន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាល ដែលទទួលស្គាល់ជាផ្លូវការដោយស្ថាប័នមានសមត្ថកិច្ច
- ទំនិញជាអំណោយមនុស្សធម៌ ឬទំនិញជំនួយ
- ទំនិញផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចេញសេចក្តីណែនាំលម្អិតកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូល និងនីតិវិធីនៃការត្រួតពិនិត្យដោយម៉ាស៊ីនស្កែន តាមបញ្ញត្តិប្រការ១ ខាងលើឱ្យមានប្រសិទ្ធភាព និងអាចធ្វើបច្ចុប្បន្នភាពស្របតាមការប្រែប្រួល និងតម្រូវការជាក់ស្តែងពីពេលមួយទៅពេលមួយតាមការចាំបាច់។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងប្រធានអង្គភាពនានាដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ តទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្ម
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ